**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ចន្ទ ៧ រោច ខែ មាឃ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០២៦*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីជំនួបពិភាក្សាការងារ រវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ
# លោកស្រី វ្ល៉ាដាន់កា អាន់ទ្រេអ៊ីវ៉ា ( Vladanka Andreeva ) អ្នកសម្របសម្រួល
# អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

នាព្រឹកថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០២៦, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី **វ្ល៉ាដាន់កា អាន់ទ្រេអ៊ីវ៉ា** (Vladanka Andreeva) អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ ( United Nations Resident Coordinator ) ប្រចាំនៅកម្ពុជា ក្នុងឱកាសដែលលោកស្រីចូលកាន់តំណែងថ្មី និងការចាប់ផ្តើមបំពេញភារកិច្ចជាផ្លូវការនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និងលោកស្រី **វ្ល៉ាដាន់កា អាន់ទ្រេអ៊ីវ៉ា** បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ រហូតមកទល់បច្ចុប្បន្ន និងបានពិភាក្សាគ្នាលើប្រធានបទសំខាន់ៗមួយចំនួន ដើម្បីពង្រឹង និងជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរ សំដៅឆ្លើយតបឱ្យចំអាទិភាព និងទាន់ពេលទៅនឹងតម្រូវការចាំបាច់បន្ទាន់ចំពោះមុខ ជាពិសេសសម្រាប់ពលរដ្ឋភៀសសឹកខ្មែរតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងប្រជាពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃដែលបានវិលត្រលប់មកកម្ពុជាវិញ ក៏ដូចជា តម្រូវការអភិវឌ្ឍន៍សម្រាប់រយៈមធ្យម និងវែងរបស់កម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានជម្រាបជូនអំពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាម និងកិច្ចអន្តរាគមរបស់រាជរដ្ឋាភិបាល ដែលបាន និងកំពុងដាក់ចេញក្រោមក្របខ័ណ្ឌកម្មវិធីគាំពារសង្គម និងវិធានការដោះស្រាយបន្ទាន់ជាបន្តបន្ទាប់ ដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាផងដែរ ។ ជនភៀសសឹកប្រមាណជាង ៤ ០០០ គ្រួសារទៀត ដែលមិនទាន់អាចត្រលប់ទៅលំនៅឋានវិញបាន រាជរដ្ឋាភិបាល កំពុងផ្តោតលើការរៀបចំប្រែក្លាយជំរំទៅជាជម្រកបណ្តោះអាសន្ន និងរៀបចំសេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានចាំបាច់ ជាមួយនឹងការជំរុញការអនុវត្តកម្មវិធីជំនួយសង្គមផ្សេងៗទៀតសម្រាប់ការគាំទ្ររយៈពេលមធ្យម និងវែង ដើម្បីឈានទៅស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឡើងវិញឱ្យបានឆាប់ ។ រាជរដ្ឋាភិបាលក៏បានទទួលជំនួយមនុស្សធម៌ និងហិរញ្ញប្បទានឥតសំណងពីមិត្តចិន និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលរាជរដ្ឋាភិបាល គ្រោងនឹងប្រើប្រាស់ជំនួយនេះសម្រាប់ការស្តារហេដ្ឋារចនាសម្ព័ន្ធខូចខាតដោយសារសង្គ្រាមឡើងវិញក្នុងពេលខាងមុខនេះ ។ ជាមួយគ្នានេះ, សម្រាប់ប្រជាពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃហើយវិលត្រលប់មកកម្ពុជាវិញ

ជាង ១ លាននាក់, រាជរដ្ឋាភិបាល បាននិងកំពុងបន្តជួយពលរដ្ឋរកការងារធ្វើក្នុងស្រុកឱ្យបានឆាប់តាមរយៈការផ្គូរផ្គង, កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមទាំង Up-Skilling និង Re-Skilling, ការបង្កើតមុខរបរខ្នាតតូច, រួមទាំងកម្មវិធីជំនួយជាច្រើនផ្សេងទៀតក្នុងការគាំទ្រ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** សូមស្វាគមន៍ចំពោះការផ្តល់ជំនួយថ្មីៗបន្ថែមពីដៃគូអភិវឌ្ឍន៍ទាំងអស់ សម្រាប់ការអភិវឌ្ឍរយៈពេលមធ្យម និងវែងរបស់កម្ពុជា និងបានស្នើសុំទីភ្នាក់ងារអង្គការសហប្រជាជាតិ ជាពិសេស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme - UNDP) បន្តផ្តល់ការគាំទ្រដល់កម្ពុជា សម្រាប់ការត្រៀមខ្លួនសម្រាប់ការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួច, ការពង្រឹងប្រព័ន្ធគាំពារសង្គម, ការរៀបចំក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល សម្រាប់ចក្ខុវិស័យរយៈពេលវែង ។

លោកស្រី **វ៉្លាដាន់កា អាន់ទ្រេឧវ៉ា** បានថ្លែងអំណរគុណចំពោះការស្វាគមន៍ដ៏កក់ក្តៅរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបានបញ្ជាក់ថា អង្គការសហប្រជាជាតិ, តាមរយៈ UNDP, ត្រៀមខ្លួនជានិច្ចក្នុងការបន្តផ្តល់ការគាំទ្រដល់របៀបវារៈអភិវឌ្ឍន៍សំខាន់ៗរបស់កម្ពុជា ជាមួយនឹងការបន្តកិច្ចសន្ទនាគោលនយោបាយ សំដៅជំរុញការអនុវត្តក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការឆ្នាំ ២០២៤-២០២៨ ឱ្យកាន់តែមានប្រសិទ្ធភាព ។ **លោកស្រី** នឹងបន្តសម្របសម្រួលជាមួយភាគីពាក់ព័ន្ធក្នុងការកៀរគរជំនួយមនុស្សធម៌ និងជំនួយបច្ចេកទេស ដើម្បីផ្តល់ការគាំទ្រដល់ពលរដ្ឋភៀសសឹក និងពលរដ្ឋដែលត្រលប់មកពីប្រទេសថៃវិញផងដែរ ។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានថ្លែងអំណរគុណសារជាថ្មី និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ព្រមទាំងបានជូនពរឱ្យលោកស្រី **វ៉្លាដាន់កា អាន់ទ្រេឧវ៉ា** និងសហការីបំពេញបេសកកម្មនៅកម្ពុជាប្រកបដោយជោគជ័យ ។